00821206



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 29 / 06 / 2012
ម៉ោង (Time/Heure): 15:38
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH Arun

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម **Silvia CARTWRIGHT**
ចៅក្រម **យ៉ា សុខន**
ចៅក្រម **Jean-Marc LAVERGNE**
ចៅក្រម **យូ អុត្តារ**

កាលបរិច្ឆេទ: ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២
ភាសាដើម: ខ្មែរ/អង់គ្លេស
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

---

# សេចក្តីសម្រេចលើកំហុសនីតិវិធីរបស់ក្រុមមេធាវីការពារក្តី នួន ជា

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
នួន ជា
អៀង សារី
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**
សុន អរុណ
Michiel PESTMAN

Victor KOPPE
Andrew IANUZZI
អាង ឧត្តម
Michael G. KARNAVAS
គង់ សំអុន
Jacques VERGÈS
Arthur VERCKEN
Anta GUISSÉ

## ១. សេចក្ដីផ្ដើម

១. បន្ទាប់ពី ក្រុមមេធាវីការពារក្ដី នួន ជា ជាពិសេសសមាជិកមេធាវីអន្តរជាតិនៃក្រុមមេធាវីនោះ មានកំហុសវិជ្ជាជីវៈក្នុងទម្រង់ដដែលៗក្នុងអំឡុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការព្រមានផ្ទាល់មាត់មួយ ចំពោះក្រុមមេធាវីការពារក្ដី នួន ជា ដោយអនុលោមតាមវិធាន ៣៨(១) នៃវិធានផ្ទៃក្នុង។ កំហុសវិជ្ជាជីវៈដែលលើកឡើងមកនេះ រួមមាន (តែមិនកំហិតត្រឹមតែ) ការរំលោភបំពានដោយចេតនាទៅលើដីកានានារបស់តុលាការ ការបញ្ចេញភស្តុតាងសម្ងាត់ ឬសម្ងាត់បំផុត ទៅសារព័ត៌មានដោយពុំមានការអនុញ្ញាត និងការធ្វើសេចក្ដីថ្លែងការណ៍នានានៅក្នុងតុលាការដោយគ្មានការគោរព ឬមិនស្របនឹងបទដ្ឋានដែលត្រូវបានទទួលស្គាល់ និងក្រមសីលធម៌នៃជំនាញវិជ្ជាជីវៈផ្នែកច្បាប់។ សេចក្ដីសម្រេចនេះផ្ដល់សំអាងហេតុចំពោះការធ្វើការព្រមានដោយផ្ទាល់មាត់ដែលបានធ្វើឡើងកាលពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១២ និងផលវិបាកនានាដែលមានដោយសារតែការព្រមាននេះ អនុលោមតាមក្របខណ្ឌ ច្បាប់នៅ អ.វ.ត.ក។

## ២. ប្រវត្តិ

### ២.១ ប្រវត្តិផ្លូវច្បាប់

២. មាត្រា ២១(៣) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (“កិច្ចព្រមព្រៀង”) តម្រូវឱ្យមេធាវីការពារក្ដី ដែលបំពេញការងារការពារក្ដីជនជាប់ចោទនៅ អ.វ.ត.ក ត្រូវបំពេញការងាររបស់ខ្លួនអនុលោមតាមច្បាប់ស្ដីពីលក្ខន្តិកៈមេធាវីកម្ពុជា និង “បទដ្ឋានដែលត្រូវបានទទួលស្គាល់ និងក្រមសីលធម៌វិជ្ជាជីវៈជំនាញផ្នែកច្បាប់”។

៣. វិធាន ៣៨(១) នៃវិធានផ្ទៃក្នុង បានផ្ដល់អំណាចឱ្យអង្គជំនុំជម្រះ ក្នុងការដាក់ទណ្ឌកម្ម ឬបដិសេធក្នុងការចូលរួមសវនាការចំពោះមេធាវីណាមួយ ក្រោយពីមានការព្រមាន ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា ការប្រព្រឹត្តិរបស់មេធាវីរូបនោះជាការប្រមាថ ធ្វើឱ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី រំលោភលើដំណើរការនីតិវិធី ឬ ផ្ទុយទៅនឹងកិច្ចព្រមព្រៀង ច្បាប់ស្ដីពីលក្ខន្តិកៈ មេធាវី

កម្ពុជា ឬបទដ្ឋានដែលត្រូវបានទទួលស្គាល់ និងក្រមសីលធម៌ជំនាញវិជ្ជាជីវៈផ្នែកច្បាប់។ វិធាន ៣៨(២) នៃវិធានផ្ទៃក្នុង ផ្តល់អំណាចឱ្យអង្គជំនុំជម្រះអាចបញ្ជូនកំហុសវិជ្ជាជីវៈនេះទៅស្ថាប័នវិជ្ជាជីវៈសមស្រប។

៤. អង្គជំនុំជម្រះធ្លាប់បានធ្វើការព្រមានជាផ្លូវការរួចមកហើយទៅកាន់មេធាវីការពារក្តី នួន ជា ជាទូទៅ ពាក់ព័ន្ធនឹងការបញ្ចេញព័ត៌មានសម្ងាត់ទៅខាងក្រៅ[១] និងជាពិសេសចំពោះលោក Michiel PESTMAN ពាក់ព័ន្ធនឹងការខកខានមិនបានអនុវត្តតាមភារកិច្ចរបស់មេធាវីការពារក្តី[២] និងការចូលជ្រៀតជ្រែកក្នុងកិច្ចការពិនិត្យផ្នែកវេជ្ជសាស្ត្រ[៣]។ នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការព្រមានផ្ទាល់មាត់បន្ថែមទៀតដល់មេធាវីការពារក្តី នួន ជា បន្ទាប់ពីមានកំហុសវិជ្ជាជីវៈនាពេលថ្មីៗនេះបន្ថែមទៀត[៤] និងបានលើកឡើងពីបំណងរបស់អង្គជំនុំជម្រះក្នុងការបញ្ជូនកំហុសវិជ្ជាជីវៈនេះទៅឱ្យគណៈមេធាវីនៅទីក្រុងអាំស្ទែរដាំ (Amsterdam) និងគណៈមេធាវីរដ្ឋញូវយ៉ក ដើម្បីដោះស្រាយ ព្រោះស្ថាប័នទាំងពីរនេះមានសមត្ថកិច្ចទៅមេធាវីអន្តរជាតិនៃក្រុមមេធាវីការពារក្តី នួន ជា។ បញ្ហានេះក៏ត្រូវបញ្ជូនទៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដែលជាស្ថាប័នដែលមេធាវីទាំងអស់ត្រូវបានចុះបញ្ជី ដើម្បីបំពេញការងារនៅ អ.វ.ត.ក ដើម្បីជ្រាបជាព័ត៌មាន ។

## ២.២ ប្រវត្តិអង្គហេតុ និងសំអាងហេតុ

៥. អង្គជំនុំជម្រះបានសង្កេតឃើញពីកំហុសវិជ្ជាជីវៈក្នុងទម្រង់ដូចៗគ្នា របស់មេធាវីការពារក្តីជនជាប់ចោទ នួន ជា។ សេចក្តីសម្រេចនេះពាក់ព័ន្ធសំខាន់ទៅនឹងការប្រព្រឹត្តិរបស់មេធាវីអន្តរជាតិពីររូប ដែលមានវត្តមានក្នុងសាលសវនាការក្នុងសំណុំរឿង ០០២/០១ (លោក PESTMAN និងលោក Andrew IANUZZI) តែមេធាវីដទៃទៀតនៅក្នុងក្រុមមេធាវីការពារក្តី នួន ជា (លោក សុន

---

[១] សេចក្តីសម្រេចលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និងលើសំណើរបស់ក្រុមមេធាវីការពារក្តី សុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម ឯកសារ E115/3 ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១១ កថាខណ្ឌ ៣៩ និង ជើងទំព័រ ៩៣។

[២] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ២៧-២៩ (អត្ថបទភាសាអង់គ្លេស)។

[៣] ប្រតិចារឹក ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៨២-៨៣ (អត្ថបទភាសាអង់គ្លេស)។

[៤] ប្រតិចារឹក ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១២ ទំព័រ ៩៧-៩៨ (អត្ថបទភាសាអង់គ្លេស)។ *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ ទំព័រ ៥, ៥៧ (អត្ថបទភាសាអង់គ្លេស)។ *សូមមើលបន្ថែម* កថាខណ្ឌ ១២ ខាងក្រោម។

អរុណា និង លោក Victor KOPPE) ជាប់ពាក់ព័ន្ធនឹងកំហុសវិជ្ជាជីវៈនេះដែរ ដោយពួកគេជាហត្ថលេខីនៃសារណាមួយចំនួន។

៦. ទោះបីកំហុសវិជ្ជាជីវៈមានចំនួនច្រើនមិនអាចរៀបរាប់ដោយឡែកៗពីគ្នាក៏ដោយ ក៏ទង្វើនៃកំហុសវិជ្ជាជីវៈនេះអាចបែងចែកទៅតាមប្រភេទមួយចំនួនដូចតទៅនេះ៖ ការបញ្ចេញព័ត៌មានសម្ងាត់ទៅខាងក្រៅដោយគ្មានការអនុញ្ញាត អាកប្បកិរិយាវាយប្រហារ មិនមានគោរព ឬអាកប្បកិរិយាដទៃទៀតក្នុងតុលាការដែលប្រាសចាកពីក្រមសីលធម៌ ការប្រើប្រាស់ពាក្យពេចន៍វាយប្រហារ ឬមិនមានការគោរព នៅក្នុងសំណើនានាជាលាយលក្ខណ៍អក្សរ ការធ្វើតំណាងមិនបានត្រឹមត្រូវនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងការខកខានមិនបានគោរពទៅតាមដីកាសម្រេចនានារបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្កើតឡើងដើម្បីការពារសិទ្ធិជនជាប់ចោទ នួន ជា។ អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា ក្នុងសេចក្តីសម្រេចនេះ អង្គជំនុំជម្រះពុំមានបំណងរៀបរាប់ឱ្យពិស្តារអំពីហេតុការណ៍ផ្សេងៗនៃកំហុសវិជ្ជាជីវៈរបស់មេធាវីការពារក្តី នួន ជា ទេ តែគ្រាន់តែចង់ផ្តល់ជាឧទាហរណ៍មួយចំនួនអំពីប្រភេទកំហុសវិជ្ជាជីវៈនីមួយៗខាងលើតែប៉ុណ្ណោះ។

## *២.២.១ ការបញ្ចេញព័ត៌មានសម្ងាត់ទៅខាងក្រៅដោយគ្មានការអនុញ្ញាត*

៧. ទោះបីអង្គជំនុំជម្រះតុលាការកំពូល និងអង្គជំនុំជម្រះសាលាដំបូង ធ្លាប់បានធ្វើការព្រមានពាក់ព័ន្ធនឹង ការបញ្ចេញភស្តុតាងសម្ងាត់ ឬសម្ងាត់បំផុតទៅខាងក្រៅកាលពីមុនក៏ដោយ ក៏មេធាវីការពារក្តី នួន ជា នៅតែបន្តសរសេរនៅទំព័រដំបូងនៅក្នុងសំណើសុំ និងសារណាជាលាយលក្ខណ៍អក្សរជាច្រើនរបស់ខ្លួន ដោយស្នើសុំថា ឯកសារនោះគួរត្រូវបានចាត់ថ្នាក់ជាឯកសារសាធារណៈ និងមានការលើកឡើងថា "ទោះជាក្នុងកាលៈទេសៈណាក៏ដោយ ក្រុមមេធាវីការពារក្តីចាត់ទុកសំណើនេះជាសាធារណៈ"[៥]។ អង្គជំនុំជម្រះសាលាដំបូងមានការព្រួយបារម្ភចំពោះសិទ្ធិដែលទាមទារដោយ

[៥] សេចក្តីសម្រេចលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និងលើសំណើរបស់ក្រុមមេធាវីការពារក្តី សុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម ឯកសារ E115/3 ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១១ កថាខណ្ឌ ៣៩; សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ឯកសារ E116/1/7 ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ៣៦-៣៨។ *សូមមើល ឧទាហរណ៍* បណ្តឹងជិតចិត្តលើកទីបីចំពោះលោកស្រីចៅក្រម Cartwright ឯកសារ E171 ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១; សំណើសុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹង ហ៊ុន សែន អនុលោមតាមវិធាន ៣៥ ឯកសារ E176 ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១; សំណើសុំឱ្យមានវិធានការជាបន្ទាន់ដោយអង្គជំនុំជម្រះដោយអនុលោមតាមវិធាន ៣៥ ឯកសារ E189 ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២

មេធាវីការពារក្តី នួន ជា ដែលលុបចោលចំណាត់ថ្នាក់ឯកសាររបស់អង្គជំនុំជម្រះសាលាដំបូង និងមានការព្រួយបារម្ភចំពោះយោបល់នេះដែលថា មេធាវីការពារក្តី នួន ជា នឹងបន្តមិនគោរពតាមការចាត់ថ្នាក់របស់អង្គជំនុំជម្រះសាលាដំបូងចំពោះឯកសារដែលបានដាក់ ដែលអាចប៉ះពាល់ជាអវិជ្ជមានដល់សន្តិសុខ និងសុវត្ថិភាពរបស់ជនរងគ្រោះឬសាក្សី ឬក៏រាំងស្ទះដល់កិច្ចដំណើរការនីតិវិធី[៦]។

### ២.២.២ អាកប្បកិរិយាវាយប្រហារ មិនមានការគោរព ឬ អាកប្បកិរិយាដទៃទៀតក្នុងតុលាការ ដែលប្រាសចាកពីក្រមសីលធម៌

៨. ច្បាប់កម្ពុជាតម្រូវឱ្យមេធាវីការពារក្តីដែលមានវត្តមាននៅ អ.វ.ត.ក ត្រូវ "សំដែងជូនចៅក្រមក្នុងភាពឯករាជ្យ និងភាពថ្លៃថ្នូរ នូវការគោរពទៅតាមមុខងារ"[៧]។ សមាជិកក្នុងក្រុមមេធាវីការពារក្តី នួន ជា បានបង្ហាញការមិនគោរពទៅតាមមុខងារនេះម្តងហើយម្តងទៀត។

៩. នៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១២ លោក IANUZZI បានអះអាងដោយមិនពិតថា បានមើលបបូរមាត់លោកស្រីចៅក្រម CARTWRIGHT ក្នុងអំឡុងពេលកិច្ចដំណើរការជំនុំជម្រះកាលពីថ្ងៃកន្លងទៅ និងបានឃើញមាត់គាត់និយាយថា "blah, blah, blah, blah" ដោយចោទប្រកាន់លោកស្រីចៅក្រមថាបង្ហាញ "ការមាក់ងាយជាប្រចាំដល់ក្រុមមេធាវីការពារក្តី នួន ជា" និងបាន "សំដែងអាកប្បកិរិយាជាចំហ និង [...] អ្វីដែលគេយល់ថា (*de rigueur*) ជាការមិនសប្បាយចិត្តចំពោះសារណាដែលចេញពីជ្រុងខាងនេះនៃ [បន្ទប់សវនាការ]"។ លោក IANUZZI បានលើកឡើងថា គាត់មិនអាចរកឃើញយុត្តិសាស្ត្រអន្តរជាតិពាក់ព័ន្ធមកគាំទ្រទឡ្ហីករណ៍របស់ខ្លួនបាន ក្រៅតែពីដក

---

កថាខណ្ឌ ១; បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹង ហ៊ុន សែន អនុលោមតាមវិធាន ៣៥ ឯកសារ E176/2/1/1 ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ១។

[៦] អង្គជំនុំជម្រះកត់សម្គាល់ដោយមានកង្វល់ចំពោះរបាយការណ៍ព័ត៌មានក្នុងស្រុកដែលបង្ហាញថា នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១២ បន្ទាប់ពីអង្គជំនុំជម្រះបានចេញការព្រមានដល់មេធាវីការពារក្តី នួន ជា បានប្រហែល ១៥ នាទី សមាជិកនៃក្រុមមេធាវីការពារក្តី នួន ជា បានបញ្ចេញឯកសារសម្ងាត់ដល់សារព័ត៌មាន (*សូមមើល មេធាវីការពារក្តី នួន ជា បានទទួលការព្រមានពីកំហុសវិជ្ជាជីវៈ* ព្រឹត្តិប័ត្រព័ត៌មាន ឌឹ ខែមបូឌា ដែលី ចេញផ្សាយថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១២; *មេធាវី នួន ជា បានទទួលការព្រមានពីទង្វើរបស់ខ្លួន* កាសែត ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១២)។

[៧] ក្រមសីលធម៌នៃមេធាវីដែលបានចុះបញ្ជីក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ប្រការ ២៤ (បកប្រែក្រៅផ្លូវការ)។

ស្រង់ពាក្យពេចន៍ក្នុងចម្រៀងមកសំអាងទៅវិញ[៨]។

១០. នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានព្រមានលោក PESTMAN ជាច្រើនដងថា ប្រសិនបើគាត់នៅតែបន្តសួរសំណួរមិនពាក់ព័ន្ធដល់សាក្សីទៀត អង្គជំនុំជម្រះនឹងសន្និដ្ឋានថា គាត់បានបញ្ចប់ការសួរសាក្សីហើយ[៩]។ លោក PESTMAN បន្តសួរសំណួរមិនពាក់ព័ន្ធទៀត ហើយអង្គជំនុំជម្រះបានសម្រេចថា គាត់អស់ពេលសម្រាប់សួរសាក្សីទៀតហើយ នៅពេលនោះលោក PESTMAN បានដកឧបករណ៍សម្រាប់ស្តាប់ ហើយគ្រវែងចោល និងស្រែកថា "នេះជារឿងគួរឱ្យអស់សំណើច"។ សំដីរបស់គាត់អាចស្តាប់ឮពេញបន្ទប់សវនាការ តែឧគ្ឃោសនស័ព្ទមិនអាចចាប់សម្លេងបាន ហេតុនេះមិនមានកត់ត្រាក្នុងប្រតិចារឹកនៃសវនាការទេ[១០]។

១១. នៅថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១២ លោក IANUZZI មានវត្តមានក្នុងបន្ទប់សវនាការដោយមានស្លាកមួយដែលមានអក្សរថា "I [heart symbol] Dada" ("ខ្ញុំ [រូបបេះដូង] ដាដា (Dada)") នៅបិទភ្ជាប់នឹងអាវផាយរបស់គាត់។ អង្គជំនុំជម្រះបានបង្គាប់ឱ្យគាត់ដកស្លាកនោះទេ។ បន្ទាប់មកលោក IANUZZI បានពោលថា "សម្រាប់ជាកំណត់ហេតុ" ស្លាកនោះតំណាងឱ្យលទ្ធិដាដានិយម (Dadaism) "ជាចលនានៅដើមសតវត្សរ៍ទី ២០ ដែលច្រានចោលហេតុផល និងមូលហេតុ ដោយគាំទ្រដល់ពាក្យគ្មានន័យខ្លឹមសារ ភាពមិនសមហេតុផល និងភាពវឹកវរ។ វាមិនដូចអ្វីដែលគេប្រាប់ខ្ញុំនៅពេលសម្រាកទេ ដែលថា ស្លាកនេះសំដៅទៅពាក្យថា "បើមិនសួរ សូមកុំឆ្លើយ" ទោះបីខ្ញុំនិយាយថា វាហាក់ដូចជាបង្ហាញពីវិធីសាស្ត្រដែលអង្គជំនុំជម្រះនេះប្រើប្រាស់សម្រាប់ក្រុមមេធាវីការពារក្តីរបស់យើងក៏ដោយ"[១១]។

### ***២.២.៣ ការប្រើប្រាស់ពាក្យពេចន៍វាយប្រហារ ឬមិនមានការគោរពនៅក្នុងសំណើនានា***

---

[៨] ប្រតិចារឹក ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១២ ទំព័រ ២-៥ ("លោកប្រធាន នៅថ្ងៃឈប់សម្រាក ខ្ញុំខិតខំប្រឹងប្រែងដែរ តែមិនអាចរកយុត្តិសាស្ត្រអន្តរជាតិបាន។ តែប្រភពទីពីរដែលខ្ញុំនៅចាំបាន ហើយប្រហែលក្មេងៗជំនាន់ក្រោយនៅក្នុងសវនាការនេះមិនដឹងពីឃ្លានេះទេ ហើយខ្ញុំសូមធ្វើការដកស្រង់ថា "តន្ត្រីករខ្លះពោលពាក្យស្មោគគ្រោកនៅផ្ទះរបស់ខ្លួន តែមិនហ៊ានប្រើពាក្យប្រមាថទេពេលកាន់ក្បាលមីក្រូ" និងថា តាមពិតវាជាការដកស្រង់ចេញពីសំដីរបស់ Dr. Dre មកពី N.W.A. ក្នុងអត្ថបទដែលមានចំណងជើងថា 'Express Yourself, Straight Outta Compton' ឆ្នាំ ១៩៨៨")។

[៩] ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២ ទំព័រ ២៩-៣០, ៣៣-៣៥, ៤១-៤២ (អត្ថបទភាសាអង់គ្លេស)។

[១០] ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២ ទំព័រ ៤៣(អត្ថបទភាសាអង់គ្លេស)។

[១១] ប្រតិចារឹក ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១២ ទំព័រ ៦, ៥៧ (អត្ថបទភាសាអង់គ្លេស)។

### *ជាលាយលក្ខណ៍អក្សរ*

១២. នៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១២ បន្ទាប់ពីមានការពិភាក្សាក្នុងបន្ទប់សវនាការពីការប្រើប្រាស់ភស្តុតាងជាឯកសារក្នុងគោលបំណងសួរដេញដោលសាក្សីណាម្នាក់នោះ អង្គជំនុំជម្រះបានចេញអនុស្សរណៈមួយដែលបញ្ជាក់ថា ឯកសារថ្មីៗត្រូវតែបំពេញតាមលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤) ដើម្បីឱ្យឯកសារទាំងនោះអាចត្រូវបានទទួលយកបាន ដោយមិនគិតពីគោលបំណងនៃការប្រើប្រាស់ឯកសារទាំងនោះឡើយ[១២]។ ទោះបីមានការពិភាក្សាយ៉ាងទូលំទូលាយនៅក្នុងតុលាការពាក់ព័ន្ធនឹងវិធាននានាដែលគ្រប់គ្រងការប្រើប្រាស់ភស្តុតាងឯកសារជាទូទៅ និងការចេញសេចក្តី-សម្រេចគាំទ្រក៏ដោយ[១៣] ក៏នៅក្នុងសំណើដែលបានដាក់ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១២ មេធាវីការពារក្តី នួន ជា "បានបញ្ជាក់សាជាថ្មីនូវជំហរដ៏មុឺងមាត់របស់ខ្លួនដែលថា វិធាន ៨៧ [...] មិនអនុវត្តពាក់ព័ន្ធនឹងសម្ភារៈភស្តុតាង [សម្រាប់សួរដេញដោល] នេះទេ" និងបានពិពណ៌នាថា ការសម្រេចរបស់អង្គជំនុំជម្រះ "ពុំមានសំអាងហេតុ និងហេតុផលត្រឹមត្រូវ"[១៤]។ នៅក្នុងសំណើដដែលមួយចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ មេធាវីការពារក្តី នួន ជា បានវាយប្រហារអង្គជំនុំជម្រះសាលាដំបូងថា "បានបដិសេធមិនបន្ធូរបន្ថយជំហរលើបញ្ហានេះ" ហើយបានអះអាងថា ខ្លួនត្រូវ "បង្ខំចិត្តអនុវត្តតាមវិធីសាស្ត្រដែលមានកំហុសរបស់អង្គជំនុំជម្រះ"[១៥]។

### *២.២.៤ ការធ្វើតំណាងមិនត្រឹមត្រូវនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង*

១៣. នៅក្នុងហេតុការណ៍មួយផ្សេងទៀត មេធាវីការពារក្តីត្រូវបានស្តីបន្ទោសក្នុងការជម្រុញយ៉ាងសកម្ម

---

[១២] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា សេចក្តីណែនាំពាក់ព័ន្ធនឹងឯកសារដែលភាគីស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះ សម្រាប់គោលបំណងនៃការសួរផ្ទៀង ឯកសារ E199 ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១២។

[១៣] *សូមមើលឧទាហរណ៍* សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូង នៃចំណុំរឿង ០០២/០១ ឯកសារ E190 ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១២។

[១៤] សេចក្តីជូនដំណឹងពីសម្ភារៈឯកសារសម្រាប់ជជីកសួរដេញដោលសាក្សី TCW-487 ឯកសារ E206 ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ១ និង ៣។

[១៥] សំណើតាមវិធាន ៨៧ សុំការដាក់ឯកសារថ្មីសម្រាប់គោលបំណងជជីកដេញដោលសាក្សី TCW-321 ឯកសារ E210 ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២។

ដល់ជនជាប់ចោទដែលខ្លួនធ្វើជាតំណាងឱ្យ បង្កឱ្យអង្គជំនុំជម្រះមានការភ័ន្តច្រឡំ។ នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានកំណត់ពេលឱ្យ នួន ជា ធ្វើសក្ខីកម្មទៅលើអង្គហេតុដែលពាក់ព័ន្ធនឹងវគ្គទីពីរនៃសវនាការ។ នៅពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធីថ្ងៃនោះ លោក PESTMAN បានស្វែងរកការអនុញ្ញាតឱ្យ នួន ជា អានសេចក្តីថ្លែងមួយដែលបានរៀបចំរួចជាសម្រេច។ ប្រធានអង្គជំនុំជម្រះបានសួរថា តើសេចក្តីថ្លែងនោះពាក់ព័ន្ធនឹងអង្គហេតុនានាក្នុងវគ្គទីពីរឬទេ? នួន ជា បានឆ្លើយតបថា៖ "សេចក្តីថ្លែងនេះមានការពាក់ព័ន្ធ"[១៦]។ ការពិតសេចក្តីថ្លែងនោះមិនពាក់ព័ន្ធនឹងវគ្គទីពីរនៃសវនាការទេ។ សហព្រះរាជអាជ្ញាបានបដិសេធ ហើយប្រធានអង្គជំនុំជម្រះបានបង្គាប់ឱ្យ នួន ជា ឈប់អានសេចក្តីថ្លែងនោះ។ បន្ទាប់ពីបានពិភាក្សាបញ្ហានេះជាមួយ នួន ជា រួច លោក PESTMAN បានប្រកាសថា "ប្រសិនបើគាត់មិនត្រូវបានអនុញ្ញាតឱ្យអានបញ្ចប់នូវសេចក្តីប្រកាសរបស់គាត់ទេ [នួន ជា] នឹងមិនធ្វើការឆ្លើយតបទៅនឹងសំណួរដែលពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល ឬក៏អង្គហេតុដែលពាក់ព័ន្ធនៅក្នុងវគ្គនេះពីឆ្នាំ ១៩៧៥ ដល់ ៧៩ នោះឡើយ"[១៧]។

១៤. នាពេលបន្ទាប់នៃថ្ងៃដដែលនោះ ក្នុងនាមអង្គជំនុំជម្រះសាលាដំបូង លោកចៅក្រម LAVERGNE បានរម្លឹកប្រាប់ភាគី និងមេធាវីការពារក្តីថា ប្រធានបទនៃសវនាការនាថ្ងៃនេះត្រូវបានជូនដំណឹងជាមុនរយៈពេលយូរហើយ ហើយអង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា ការអនុញ្ញាតឱ្យកូនក្តីរបស់ខ្លួន នួន ជា អះអាងថា សេចក្តីប្រកាសនេះពាក់ព័ន្ធនឹងអង្គហេតុ តែការពិតមិនពាក់ព័ន្ធនោះ សហមេធាវីការពារក្តីហាក់បានជម្រុញឱ្យ នួន ជា បង្កឱ្យអង្គជំនុំជម្រះមានការភ័ន្តច្រឡំ។ អង្គជំនុំ-ជម្រះសាលាដំបូងបានលើកឡើងថា លោក PESTMAN កំពុងប៉ុនប៉ង "ចង់បោកប្រាសអង្គជំនុំ-ជម្រះសាលាដំបូងតាមរបៀបមួយមិនសមរម្យ ដែលផ្ទុយទៅនឹងវិធាននៃករណីកិច្ចសាស្ត្រ ដែលមេធាវីនៅចំពោះមុខតុលាការនេះត្រូវតែអនុវត្ត" និងថា "អាកប្បកិរិយារបស់មេធាវីនេះ គឺប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បញ្ញាករណីកិច្ចសាស្ត្រ។ ដូច្នេះ [អង្គជំនុំជម្រះសាលាដំបូង] រក្សាសិទ្ធិនៅក្នុងការចាត់វិធានការទៅតាមលក្ខណៈសមស្រប ដើម្បីឆ្លើយតបទៅនឹងការប្រព្រឹត្តបែបនេះ"[១៨]។

---

[១៦] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៤ (អត្ថបទភាសាអង់គ្លេស)។

[១៧] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ១៧ (អត្ថបទភាសាអង់គ្លេស)។

[១៨] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ២៧-២៨ (អត្ថបទភាសាអង់គ្លេស)។

## ២.២.៥ កំហុសវិជ្ជាជីវៈដែលអាចប៉ះពាល់ជាអវិជ្ជមានដល់ការការពារក្តីជនជាប់ចោទ នួន ជា រួមទាំងការមិនគោរពតាមដីកាសម្រេចនានារបស់អង្គជំនុំជម្រះ

១៩. នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យភាគីដាក់បញ្ជីឯកសារដែលខ្លួនមានបំណងចង់ដាក់ក្នុងសំណុំរឿង ០០២ អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង[១៩]។ ភាគីទាំងអស់បានអនុវត្តតាម យ៉ាងហោចណាស់ក៏ក្នុងកម្រិតណាមួយដែរ លើកលែងតែមេធាវីការពារក្តី នួន ជា[២០]។ នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានបង្គាប់ឱ្យភាគីដាក់បញ្ជីដែលបានកែសម្រួល[២១]។ មេធាវីការពារក្តី នួន ជា បដិសេធមិនបានដាក់បញ្ជីនេះទេ ចំណែកឯភាគីទាំងអស់បានធ្វើតាមសេចក្តីបង្គាប់នេះ[២២]។ អង្គជំនុំជម្រះបានព្រមានភាគីថា ការខកខានមិនបានគោរពតាមដីកាបង្គាប់ទាំងនេះ នឹងកំហិតលទ្ធភាពភាគីក្នុងការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះក្នុងអំឡុងពេលសវនាការ និងបានបង្គាប់ឱ្យភាគីផ្តល់ជូននូវបញ្ជីឯកសារដែលបានកែសម្រួលសម្រាប់ពេលសវនាការបីសប្តាហ៍ដំបូងត្រឹមថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១១[២៣]។ ជាថ្មីម្តងទៀត ភាគីទាំងអស់បានអនុវត្តតាម លើកលែងតែមេធាវីការពារក្តី នួន ជា[២៤]។ ចុងក្រោយនៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ មេធាវីការពារក្តី នួន ជា បានដាក់បញ្ជីឯកសារមួយចំនួនតូច

---

[១៩] ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ឯកសារ E9 ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១។

[២០] *សូមមើល* សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ឯកសារ E190 ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ៣។

[២១] ប្រតិចារឹក ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១២ ទំព័រ ២៥ (អត្ថបទភាសាអង់គ្លេស)។

[២២] *សូមមើល* សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ឯកសារ E190 ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ៤។

[២៣] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និង ចម្លើយតបទៅនឹងសំណើ E109/5 ឯកសារ E131/1 ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១។

[២៤] *សូមមើល* បញ្ជីឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងទៅនឹងសវនាការនៅដំណាក់កាលដំបូង ឯកសារ E131/1/2 ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១; បញ្ជីឯកសាររបស់លោក អៀង សារី សម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង ឯកសារ E131/1/3, ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១; សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីឯកសារដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះដែលជាប់ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញទាំងឡាយដែលត្រូវកោះហៅក្នុងអំឡុងពេលបីសប្តាហ៍ដំបូងនៃសវនាការជាមួយនឹងឧបសម្ព័ន្ធ ក សម្ងាត់ ឯកសារ E131/1/4, ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១; ការចង្អុលបង្ហាញពាក់ព័ន្ធនឹងសាក្សី ព្រមទាំងឯកសារនានាសម្រាប់ដំណាក់កាលទីមួយនៃការជំនុំជម្រះដំបូង ឯកសារ E131/1/6, ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១។

មកអង្គជំនុំជម្រះ[២៥]។

១៦. ការខកខានរបស់មេធាវីការពារក្ដី នួន ជា មិនបានអនុវត្តតាមការណែនាំរបស់អង្គជំនុំជម្រះអាច ប៉ះពាល់ជាអវិជ្ជមានយ៉ាងច្រើនដល់លទ្ធភាពរបស់ខ្លួនក្នុងការពឹងផ្អែកលើភស្តុតាងឯកសារ ក្នុង សំណុំរឿង ០០២ ទាំងមូល។ ជាលទ្ធផលនៃកំហុសវិជ្ជាជីវៈនេះ អង្គជំនុំជម្រះត្រូវបង្ខំចិត្តអនុវត្ត ឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីបញ្ចៀសមិនឱ្យខូចប្រយោជន៍ដល់ នួន ជា ដោយសារតែក្រុមមេធាវី ការពារក្ដីរបស់គាត់ខកខានមិនបំពេញការងាររបស់ខ្លួន[២៦]។

១៧. នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាមួយដើម្បីកំណត់កាល បរិច្ឆេទក្នុងការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ក្នុងនាមសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្ដី ទាំងអស់[២៧]។ សហព្រះរាជអាជ្ញាបានទទួលរយៈពេល ០២ ថ្ងៃសម្រាប់ធ្វើសេចក្ដីសន្និដ្ឋានចោទ ប្រកាន់របស់ខ្លួន ដោយចាប់ផ្ដើមពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១។ ក្រុមមេធាវីការពារក្ដីបាន ទទួលព័ត៌មានថា ក្រុមនីមួយៗនឹងមានរយៈពេលកន្លះថ្ងៃដើម្បីឆ្លើយតប។ ហេតុនេះ ភាគីទាំងអស់ បានទទួលព័ត៌មានថា ដោយសារជនជាប់ចោទម្នាក់ត្រូវបានផ្អាកមិនចូលរួមការជំនុំជម្រះនោះ សហព្រះរាជអាជ្ញាត្រូវចំណាយពេលត្រឹមតែមួយថ្ងៃកន្លះប៉ុណ្ណោះសម្រាប់ធ្វើសេចក្ដីសន្និដ្ឋានចោទ ប្រកាន់ ហើយអាចថា ភាគីផ្សេងទៀតអាចនឹងធ្វើសេចក្ដីសន្និដ្ឋានសង្ខេបរបស់ខ្លួនមុនពេលកំណត់ បន្តិច[២៨]។

១៨. នៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ នៅពេលអង្គជំនុំជម្រះសាលាដំបូងអញ្ជើញឱ្យធ្វើសេចក្ដី សន្និដ្ឋានសង្ខេបរបស់ខ្លួនក្នុងនាម នួន ជា នៅវេលាម៉ោងប្រមាណ ១:៣០ រសៀល (ពោលគឺបន្ទាប់

---

[២៥] បញ្ជីឯកសារដែលត្រូវដាក់នៅដំណាក់កាលដំបូងនៃការជំនុំជម្រះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E131/1/13 ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២។

[២៦] *សូមមើល* សេចក្ដីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ឯកសារ E190 ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ៣៥-៣៧។

[២៧] ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២ ឯកសារ E131 ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១។

[២៨] ប្រតិចារិក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ១១ 11 (អត្ថបទភាសាអង់គ្លេស) (ដែលបង្ហាញថា សហព្រះរាជអាជ្ញា មានពេលមួយថ្ងៃកន្លះ ដើម្បីធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់)។

ពីសហព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់រយៈពេលមួយថ្ងៃកន្លះ) នោះ លោក PESTMAN បានស្នើសុំពន្យារពេលធ្វើសេចក្តីសន្និដ្ឋានរហូតដល់ថ្ងៃបន្ទាប់វិញ ដោយយកដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ជាមូលដ្ឋាន និងបានអះអាងថា "សេចក្តីសន្និដ្ឋានចោទប្រកាន់ខ្លីបែបនេះ ធ្វើឱ្យយើងខ្ញុំមានការភ្ញាក់ផ្អើលបន្តិចដែរ"[២៩]។ មកទល់នឹងថ្ងៃនោះ កិច្ចដំណើរការនីតិវិធីប្រឆាំង នួន ជា បានបន្តរយៈពេលជាង ០៤ ឆ្នាំមកហើយ ដែលសមាជិកទាំងអស់នៅក្នុងក្រុមមេធាវីការពារក្តី នួន ជា ដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចនេះ បានចូលរួមតំណាងជនជាប់ចោទក្នុងពេលភាគច្រើននៃដំណាក់កាលមុនសវនាការនេះ[៣០]។ ហេតុនេះ ដើម្បីបញ្ចៀសមិនឱ្យខូចប្រយោជន៍ដល់ នួន ជា នោះ អង្គជំនុំជម្រះសាលាដំបូងបន្ធូរចិត្តអនុញ្ញាតឱ្យមេធាវីការពារក្តី នួន ជា ដាក់សេចក្តីសន្និដ្ឋានសង្ខេបរបស់ខ្លួនជាលាយលក្ខណ៍អក្សរ ទោះបីតាមពិត ឯកសារបែបនេះពុំមានគុណសម្បត្តិត្រូវបញ្ចូលក្នុងសំណុំរឿងក៏ដោយ[៣១]។

**សម្រាប់សំអាងហេតុទាំងអស់ខាងលើ អង្គជំនុំជម្រះសាលាដំបូង៖**

**ជូនដំណឹង** ដល់មេធាវីការពារក្តី នួន ជា ដែលពាក់ព័ន្ធថា អង្គជំនុំជម្រះបញ្ជូនករណីកំហុសវិជ្ជាជីវៈរបស់ពួកគេទៅឱ្យគណៈមេធាវីអាំស្ទែរដាំ (Amsterdam) និងគណៈមេធាវីរដ្ឋញូវយ៉ក ដើម្បីចាត់វិធានការណ៍សមស្រប និងជូនដំណឹងដល់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាពីបញ្ហានេះ។

**ស្នើសុំ** ឱ្យគណៈមេធាវីអាំស្ទែរដាំ (Amsterdam) និងគណៈមេធាវីរដ្ឋញូវយ៉ក ជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូងវិញទៅតាមពេលវេលាសមរម្យពីលទ្ធផលនៃដំណើរការដោះស្រាយករណីនេះ និងវិធានការដែលយកមកអនុវត្តចំពោះកំហុសវិជ្ជាជីវៈនេះ។

---

[២៩] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៧២ (អត្ថបទភាសាអង់គ្លេស)។

[៣០] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឯកសារ D3 ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧; ការចាត់តាំងលោក សុន អរុណ ជាមេធាវីការពារក្តី នួន ជា ដោយ អង្គភាពគាំពារការការពារក្តី ឯកសារ A28 ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០០៧; ការទទួលស្គាល់លោកមេធាវី Michiel PESTMAN ជាមេធាវីការពារក្តី នួន ជា ឯកសារ D51 ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៧។

[៣១] *សូមមើល* សំណើសុំដាក់ឯកសារក្នុងសំណុំរឿង ឯកសារ E146 ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១។

**ធ្វើការព្រមានជាថ្មី** ដល់មេធាវីការពារក្តី នួន ជា មិនឲ្យមានកំហុសវិជ្ជាជីវៈផ្សេងទៀតទេ។ និង

**កត់សម្គាល់ថា** ជាលទ្ធផលនៃសេចក្តីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងអាចនឹងចាត់វិធានការផ្សេងពីគណៈមេធាវីនីមួយៗនោះ រួមទាំងការសម្រេចដាក់ទណ្ឌកម្ម ឬបដិសេធការចូលរួមសវនាការរបស់សមាជិកណាម្នាក់នៃក្រុមមេធាវីការពារក្តី នួន ជា ដែលខកខានមិនបានគោរពតាមការព្រមាននេះ។

ភ្នំពេញ, ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

**និល ណុន**